មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៦ កើត ខែ ជេស្ឋ ឆ្នាំ កុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០២០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

អនុវត្តន៍ដូចបញ្ជាក់ខាងលើ
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...ស.ណ...

អនុក្រឹត្យ
ស្តីពី
ការតាំងសិប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៨២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិក:មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤១ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិក:ដោយម្លែក នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៥៤ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

សម្រេច

មាត្រា ១ .- តាំងសិប់ក្នុងក្របខ័ណ្ឌដល់មន្ត្រីរាជការចំនួន ០៨ រូប ទៅក្នុងឋានន្តរស័ក្តិគ្រូបង្រៀនកម្រិតមូលដ្ឋាន នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន នៅក្រសួងធម្មការ និងសាសនា ចាប់ពីថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១៨ ដូចមានរាយនាមខាងក្រោម ៖

១-លោក **សៀម ខាសនា**	គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ ៤
២-លោក **ខឿន ធំ**	គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ ៤
៣-លោក **តាង សុតា**	គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ ៤
៤-លោក **កឹង សុជន**	គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ ៤

៥-លោក **កើត តួន**	គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ ៤
៦-លោក **ឆួន ម៉ាក់**	គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ ៤
៧-លោក **រឿន ឥតៀ**	គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ ៤
៨-លោក **ឈាង សំណាង**	គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ ៤

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៦ កើត ខែ ផល្គុន ឆ្នាំ កុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០២០

ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

អនុស្ថានទទួល
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៦ សសរ

សេចក្តីសម្រេច
ស្តីពី
ការបង្កើតគណៈកម្មការអន្តរក្រសួង
ដើម្បីប្រយុទ្ធនឹងជំងឺកូវីដ១៩ (COVID-19)

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ និងឆ្លើយតបការឆ្លងរាលដាលជាអន្តរជាតិនៃជំងឺនៅតាមច្រកចេញចូល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

សម្រេច

ប្រការ១.-

បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីប្រយុទ្ធនឹងជំងឺកូវីដ១៩ (COVID-19) ដែលមានសមាសភាពដូចខាងក្រោម៖

១- រដ្ឋមន្ត្រីក្រសួងសុខាភិបាល	ប្រធាន
២- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី	អនុប្រធាន
៣- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ	អនុប្រធាន
៤- រដ្ឋលេខាធិការក្រសួងការពារជាតិ	អនុប្រធាន
៥- រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ	អនុប្រធាន
៦- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	អនុប្រធាន
៧- រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា	សមាជិក
៨- រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	សមាជិក

៩- រដ្ឋលេខាធិការក្រសួងបរិស្ថាន	សមាជិក
១០- រដ្ឋលេខាធិការក្រសួងព័ត៌មាន	សមាជិក
១១- រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន	សមាជិក
១២- រដ្ឋលេខាធិការក្រសួងទេសចរណ៍	សមាជិក
១៣- រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ	សមាជិក
១៤- រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល	សមាជិក
១៥- អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត	សមាជិក។

ប្រការ២ ..

គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ១៩ (COVID-19) មានភារកិច្ច ដូចតទៅ៖

- រៀបចំផែនការឆ្លើយតបជំងឺ COVID-19 ទៅតាមការវិវត្តន៍នៃការរីករាលដាលនៃវីរុស
- អនុវត្តសកម្មភាពតាមផែនការដែលបានអនុម័តដោយប្រមុខរាជរដ្ឋាភិបាល
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តនៃការប្រយុទ្ធនឹងជំងឺ COVID-19
- លើកទិសដៅប្រតិបត្តិជាយថាហេតុតាមស្ថានភាពជាក់ស្តែងនៃការរាតត្បាតជំងឺ COVID-19
- គោរពរាយការណ៍ជាប្រចាំជូនប្រមុខរាជរដ្ឋាភិបាល អំពីការវិវត្តន៍នៃជំងឺ COVID-19
- ចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

ប្រការ៣ ..

គណៈកម្មការអន្តរក្រសួងនេះ មានលេខាធិការដ្ឋាន ដែលមានទីតាំងស្ថិតនៅនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាល។

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិបង្កើតអនុគណៈកម្មការបច្ចេកទេសផ្សេងទៀតតាមការចាំបាច់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មការអន្តរក្រសួង។

ប្រការ៤ ..

គណៈកម្មការអន្តរក្រសួងនេះ ប្រើកញ្ចប់ថវិកាជាតិ និងជំនួយផ្សេងៗពីដៃគូអភិវឌ្ឍ និងសប្បុរសជន និងមានសិទ្ធិប្រើត្រារបស់ក្រសួងសុខាភិបាល។

ប្រការ៥ ..

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៦ ..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ព្រមទាំងសមាសភាពដែលមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៤ រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០២០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ÷
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ឧបទ្ធកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ឧបទ្ធកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.៦០០.....សហវ...

ប្រកាសអន្តរក្រសួង
ស្តីពី
ការបង្កើតរដូវទេយ្យបុរេប្រទានសម្រាប់ឆ្នាំ២០២០
របស់នាយកដ្ឋានឧត្តមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ **រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៩/០២៥ ចុះថ្ងៃសុក្រ ៩រោច ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២០
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងអប់រំយុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែ តុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៨៤ មាត្រា៨៥ មាត្រា ៨៦ និងមាត្រា ៨៧ នៃអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកានៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៨ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសលេខ១១២៩ សហវ.ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨ ស្តីពីការកែសម្រួល និងការបង្កើតបន្ថែមគណនី និងអនុគណនីនៃចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ១៦១៥ សហវ.ប្រក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការបង្កើតបន្ថែមគណនី និងអនុគណនី នៃប្លង់គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ២៥១ សហវ.ប្រក ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងនាយកដ្ឋានឧត្តមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

ប្រការ១ ._

ត្រូវបានបង្កើតរដ្ឋទេយ្យបុរេប្រទានថវិកាកម្មវិធីជំពូក៦០ (ការទិញ), ជំពូក៦១ (សេវាកម្ម) និង៦២ (អត្ថប្រយោជន៍សង្គម) នៅនាយកដ្ឋានឧត្តមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា សម្រាប់មុខសញ្ញាចំណាយដូចមានចែងក្នុងប្រការ៥ថ្មី នៃប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៨ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ ។

តារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

ប្រការ២ ._

ចំនួនទឹកប្រាក់មួយជុំបង្វិលនៃរដ្ឋទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទាន ។

ប្រការ៣ ._

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

ប្រការ ៤ ._

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និង អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ នាយកដ្ឋានហិរញ្ញវត្ថុ និងនាយកដ្ឋានឧត្តមសិក្សា ប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួង នេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ២០២០

ឧបនាយករដ្ឋមន្ត្រី	**រដ្ឋមន្ត្រី**
រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	**ក្រសួងអប់រំ យុវជន និងកីឡា**
អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន	បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

កន្លែងទទួល

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមុខងារសាធារណៈ
-ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៨
-រាជកិច្ច
-ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
នាយកដ្ឋានឧត្តមសិក្សា

តារាងឧបសម្ព័ន្ធផ្តល់ជូនទៅឲ្យប្រុះប្រធានថវិកាកម្មវិធី
តាមចំណាត់ថ្នាក់សេដ្ឋកិច្ចឆ្នាំ២០២០ របស់នាយកដ្ឋានឧត្តមសិក្សា

ឯកតា: រៀល

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ	ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២០	ឥណទាន ដែលប្រើសរើស	ឥណទាន រដ្ឋទេយ្យប្រុះប្រទាន	ឥណទាន ខុទាក់ធម្មតា	ឥណទានទំនិញ រដ្ឋទេយ្យប្រុះប្រទាន	ភាគរយ
				១	២	៣	៤=២-៣	៥=៣/៤%	៦=៣/២
			សរុប	6,130,200,000	4,383,600,000	2,329,600,000	2,054,000,000	582,400,000	53.14%
60			ការទិញ	2,297,700,000	1,767,700,000	540,000,000	1,227,700,000	135,000,000	30.55%
	6001		សម្ភារផ្គត់ផ្គង់ថែទាំ	236,300,000	236,300,000	133,100,000	103,200,000	33,275,000	56.33%
		60011	សម្ភារផ្គត់ផ្គង់សម្អាត និងអនាម័យ	48,900,000	48,900,000	37,900,000	11,000,000	9,475,000	77.51%
		60012	សម្ភារផ្គត់ផ្គង់សម្រាប់ថែទាំអគារ ប្រាសាទ និងសំណង់ផ្សេងៗ	54,400,000	54,400,000	34,400,000	20,000,000	8,600,000	63.24%
		60014	សម្ភារផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារឧបករណ៍	29,800,000	29,800,000	24,800,000	5,000,000	6,200,000	83.22%
		60015	ប្រេងឥន្ធនៈ និងប្រេងរំអិល	101,200,000	101,200,000	34,000,000	67,200,000	8,500,000	33.60%
		60018	សម្ភារផ្គត់ផ្គង់ថែទាំផ្សេងៗ	2,000,000	2,000,000	2,000,000	-	500,000	100.00%
	6002		សម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាល	599,100,000	599,100,000	107,300,000	491,800,000	26,825,000	17.91%
		60021	សម្ភារការិយាល័យ	234,700,000	234,700,000	57,100,000	177,600,000	14,275,000	24.33%
		60022	សៀវភៅមើល និងឯកសារ	34,800,000	34,800,000	12,800,000	22,000,000	3,200,000	36.78%
		60023	ការបោះពុម្ព	329,600,000	329,600,000	37,400,000	292,200,000	9,350,000	11.35%
	6003		ស្បៀងអាហារ និងផលិតផលកសិកម្ម	201,300,000	201,300,000	160,400,000	40,900,000	40,100,000	79.68%
		60032	ចំណីសត្វ	31,700,000	31,700,000	24,800,000	6,900,000	6,200,000	78.23%
		60033	ឱជ និងកូនក្តួជាតិ	33,300,000	33,300,000	28,300,000	5,000,000	7,075,000	84.98%
		60034	ផលិតផលការពារសុខុមាលភាពក្តួជាតិ និងដី	40,600,000	40,600,000	27,600,000	13,000,000	6,900,000	67.98%
		60035	ឱជសត្វ	35,300,000	35,300,000	24,300,000	11,000,000	6,075,000	68.84%
		60036	ឱសថ និងគ្រឿងគីមីសម្រាប់បសុពេទ្យ	22,400,000	22,400,000	22,400,000	-	5,600,000	100.00%
		60037	ស្បៀងសម្រាប់ផ្នែករដ្ឋបាល	38,000,000	38,000,000	33,000,000	5,000,000	8,250,000	86.84%
	6004		សំលៀកបំពាក់ និងការតុបតែង	37,500,000	37,500,000	23,900,000	13,600,000	5,975,000	63.73%
		60041	ឯកសណ្ឋាន	9,600,000	9,600,000	6,000,000	3,600,000	1,500,000	62.50%
		60042	សំលៀកបំពាក់ការពារសុវត្ថិភាព	27,900,000	27,900,000	17,900,000	10,000,000	4,475,000	64.16%
	6005		សម្ភារគ្រឿងចាប សង្ហារឹម និងសម្ភារបរិក្ខារ	682,500,000	666,500,000	96,300,000	570,200,000	24,075,000	14.45%
		60051	សម្ភារនិងបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា	290,000,000	290,000,000	17,000,000	273,000,000	4,250,000	5.86%
		60052	សង្ហារឹម	90,000,000	90,000,000	17,000,000	73,000,000	4,250,000	18.89%
		60053	សម្ភារប្រើប្រាស់	59,300,000	59,300,000	44,300,000	15,000,000	11,075,000	74.70%
		60054	សម្ភារ និងឧបករណ៍ដឹកជញ្ជូន	14,000,000	-	-	-	-	-
		60055	សម្ភារនិងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា	227,200,000	227,200,000	18,000,000	209,200,000	4,500,000	7.92%
		60058	សម្ភារគ្រឿងចាប សង្ហារឹម និងសម្ភារបរិក្ខារផ្សេងៗ	2,000,000	-	-	-	-	-
	6006		ថាមពលនិងទឹក	514,000,000	-	-	-	-	-
		60061	អគ្គិសនី	460,000,000	-	-	-	-	-

ចំណូល	គណនេយ្យ	អនុគណនេយ្យ	ចំណាត់ថ្នាក់ចំណាយ	ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២០	ឥណទានដែលត្រឹសរើស	ឥណទានរដ្ឋទេយ្យបុរេប្រទាន	ឥណទានទូទាត់ជម្ពរ	ឥណទានទំនិញរដ្ឋទេយ្យបុរេប្រទាន	ភាគរយ
				១	២	៣	៤=២-៣	៥=៣/៤%	៦=៣/២
		60062	ទឹក	54,000,000	-	-	-	-	-
	6007		សម្ភារបរិក្ខារថែទាំសុខភាព	27,000,000	27,000,000	19,000,000	8,000,000	4,750,000	70.37%
		60072	សម្ភារបរិក្ខារពេទ្យ	27,000,000	27,000,000	19,000,000	8,000,000	4,750,000	70.37%
61			សេវាកម្ម	2,612,400,000	2,611,400,000	1,785,100,000	826,300,000	446,275,000	68.36%
	6101		កិច្ចសន្យានៃការផ្តល់សេវាជាមួយសហគ្រាស	1,000,000	-	-	-	-	-
		61011	សេវាអនាម័យ	1,000,000	-	-	-	-	-
	6102		ការជួលមធ្យោបាយដឹកជញ្ជូន	44,000,000	44,000,000	29,000,000	15,000,000	7,250,000	65.91%
		61021	ការជួលមធ្យោបាយដឹកជញ្ជូន	44,000,000	44,000,000	29,000,000	15,000,000	7,250,000	65.91%
	6104		សោហ៊ុយបណ្តុះបណ្តាល ក្នុងនិងក្រៅប្រទេស	68,000,000	68,000,000	43,000,000	25,000,000	10,750,000	63.24%
		61041	សោហ៊ុយបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស	68,000,000	68,000,000	43,000,000	25,000,000	10,750,000	63.24%
	6105		ការថែទាំនិងជួសជុល	462,400,000	462,400,000	196,400,000	266,000,000	49,100,000	42.47%
		61051	ការថែទាំដីធ្លី សួនច្បារ ព្រៃឈើ តំបន់ឆ្នេរ និងផែនទីសាទ	50,000,000	50,000,000	32,000,000	18,000,000	8,000,000	64.00%
		61052	ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ	215,600,000	215,600,000	40,000,000	175,600,000	10,000,000	18.55%
		61054	ការថែទាំបណ្តាញផ្សេងៗ	65,000,000	65,000,000	37,000,000	28,000,000	9,250,000	56.92%
		61056	ការថែទាំ និងជួសជុលមធ្យោបាយដឹកជញ្ជូន	40,000,000	40,000,000	35,000,000	5,000,000	8,750,000	87.50%
		61057	ការថែទាំនិងជួសជុលសម្ភារៈ និងឧបករណ៍បច្ចេកទេស	80,800,000	80,800,000	50,400,000	30,400,000	12,600,000	62.38%
		61058	ការថែទាំនិងជួសជុលផ្សេងៗ	11,000,000	11,000,000	2,000,000	9,000,000	500,000	18.18%
	6108		សោហ៊ុយដឹកជញ្ជូន	12,000,000	12,000,000	7,000,000	5,000,000	1,750,000	58.33%
		61081	សម្ភារៈ និងទំនិញ	12,000,000	12,000,000	7,000,000	5,000,000	1,750,000	58.33%
	6110		ទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយ	589,700,000	589,700,000	431,500,000	158,200,000	107,875,000	73.17%
		61101	សោហ៊ុយទទួលភ្ញៀវជាតិ	34,300,000	34,300,000	22,250,000	12,050,000	5,562,500	64.87%
		61102	សោហ៊ុយទទួលភ្ញៀវបរទេស	33,300,000	33,300,000	30,250,000	3,050,000	7,562,500	90.84%
		61103	ប្រជុំ សិក្ខាសាលា និងសន្និសីទ	430,700,000	430,700,000	318,000,000	112,700,000	79,500,000	73.83%
		61104	ចំណាយរៀបចំពិធីបុណ្យ	45,000,000	45,000,000	30,000,000	15,000,000	7,500,000	66.67%
		61105	ចំណាយសម្រាប់វគ្គអនុស្សាវរីយ៍ នៅក្នុងនិងក្រៅប្រទេស	29,200,000	29,200,000	17,000,000	12,200,000	4,250,000	58.22%
		61107	ការឃោសនានិងផ្សព្វផ្សាយព័ត៌មានសាធារណៈ	17,200,000	17,200,000	14,000,000	3,200,000	3,500,000	81.40%
	6112		សោហ៊ុយបេសកកម្មក្នុងប្រទេស	1,003,700,000	1,003,700,000	920,200,000	83,500,000	230,050,000	91.68%
		61121	សោហ៊ុយដឹកជញ្ជូន	148,700,000	148,700,000	143,400,000	5,300,000	35,850,000	96.44%
		61122	សោហ៊ុយបេសកកម្ម	113,700,000	113,700,000	105,700,000	8,000,000	26,425,000	92.96%
		61123	សោហ៊ុយស្នាក់នៅ	741,300,000	741,300,000	671,100,000	70,200,000	167,775,000	90.53%
	6113		សោហ៊ុយបេសកកម្មក្រៅប្រទេស	363,300,000	363,300,000	133,300,000	230,000,000	33,325,000	36.69%
		61131	សោហ៊ុយដឹកជញ្ជូន	93,500,000	93,500,000	36,000,000	57,500,000	9,000,000	38.50%
		61132	សោហ៊ុយបេសកកម្ម	52,700,000	52,700,000	19,600,000	33,100,000	4,900,000	37.19%
		61133	សោហ៊ុយស្នាក់នៅ	217,100,000	217,100,000	77,700,000	139,400,000	19,425,000	35.79%
	6114		សោហ៊ុយប្រៃសណីយ៍ និងទូរគមនាគមន៍	68,300,000	68,300,000	24,700,000	43,600,000	6,175,000	36.16%
		61141	សោហ៊ុយប្រៃសណីយ៍	4,600,000	4,600,000	4,600,000	-	1,150,000	100.00%
		61142	សោហ៊ុយទូរគមនាគមន៍	63,700,000	63,700,000	20,100,000	43,600,000	5,025,000	31.55%

ជំពូក	គណនេយ្យ	អនុគណនេយ្យ	ចំណាត់ថ្នាក់ចំណាយ	ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២០	កំណែទាន ដែលត្រើសរើស	កំណែទាន រដ្ឋទេយ្យបុរេប្រទាន	កំណែទាន ខុទាក់ទងគ្នា	កំណែទាន១ដុំបន្ថែម រដ្ឋទេយ្យបុរេប្រទាន	ភាគរយ
				១	២	៣	៤=២-៣	៥=៣/៤ដុំ	៦=៣/២
62			អត្ថប្រយោជន៍សង្គម	1,220.100,000	4,500,000	4,500,000	-	1,125,000	100.00%
	6202		ជំនួយសង្គមដល់ប្រជាពលរដ្ឋ	215,600,000	-	-	-	-	-
		62025	អាហារូបករណ៍សម្រាប់ការសិក្សា-ស្រាវជ្រាវក្នុងប្រទេស	27,600,000	-	-	-	-	-
		62026	អាហារូបករណ៍សម្រាប់ការសិក្សា-ស្រាវជ្រាវក្រៅប្រទេស	188,000,000	-	-	-	-	-
	6203		ឧបត្ថម្ភដល់អង្គភាពដែលមានលក្ខណៈសង្គម និងវប្បធម៌	4,500,000	4,500,000	4,500,000	-	1,125,000	100.00%
		62033	ឧបត្ថម្ភដំណើរលេងហែ និងសិក្សា	4,500,000	4,500,000	4,500,000	-	1,125,000	100.00%
	6206		ចំណាយអន្តរាគមន៍ផ្នែកសង្គមកិច្ចនិងវប្បធម៌	1,000,000,000	-	-	-	-	-
		62061	ចំណាយលើការប្រឡង-ប្រឡងប្រជែង	1,000,000,000	-	-	-	-	-

បានឃើញ និង ពិនិត្យត្រឹមត្រូវ
ថ្ងៃ... ខែ... ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ថ្ងៃទី... ខែ... ឆ្នាំ២០២០
រាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ២០២០
៤. ប្រតិភូអាជ្ញាធរចូលបន្តុកជា
អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយ

ម៉ឹង ប្បានសុវណ្ណអធិច្ចាសីលា

បានឃើញ និង ពិនិត្យត្រឹមត្រូវ
ថ្ងៃ... ខែ... ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ថ្ងៃទី... ខែ... ឆ្នាំ២០២០
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែមករា ឆ្នាំ២០២០
៥. ប្រតិភូអាជ្ញាធរចូលបន្តុកជា
អគ្គនាយកនៃអគ្គនាយកដ្ឋានថតិកា
ប្រធានក្រុមការងារពិនិត្យហិរញ្ញវត្ថុ
អមក្រសួងអប់រំ យុវជន និងកីឡា

គិន_កោសល្យ

បានឃើញ និង ឯកភាព
ថ្ងៃ... ខែ... ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមករា ឆ្នាំ២០២០
ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមករា ឆ្នាំ២០២០
បានឃើញ និង ពិនិត្យត្រឹមត្រូវ
ថ្ងៃ... ខែ... ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែមករា ឆ្នាំ២០២០
ប្រធានអង្គភាពថតិកានាយកដ្ឋានឧត្តមសិក្សា

គង់_ភូមីកា

បានឃើញ និង ឯកភាព
ថ្ងៃ... ខែ... ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែមករា ឆ្នាំ២០២០
រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.៨០៤.....សហវ...

ប្រកាសអន្តរក្រសួង
ស្តីពី
ការបង្កើតរដ្ឋទេយ្យបុរេប្រទានសម្រាប់ឆ្នាំ២០២០
របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៩/០២៥ ចុះថ្ងៃ ២០ ខែ ធ្នូ ឆ្នាំ ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែ តុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៨៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកានៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសលេខ១៥៩៩ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម

សម្រេច

ប្រការ១ ._

ត្រូវបានបង្កើតរដ្ឋទេយ្យបុរេប្រទានថវិកាកម្មវិធី ជំពូក៦០"ការទិញ" ជំពូក៦១"សេវាកម្ម" របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម សម្រាប់មុខសញ្ញាចំណាយដូចមានចែងក្នុងប្រការ៥ថ្មី នៃប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ ។

តារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

ប្រការ២ ._

ចំនួនទឹកប្រាក់មួយដុំបង្វិលនៃរដ្ឋទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទាន ។

ប្រការ៣ ._

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

ប្រការ ៤ ._

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និង អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការទូទៅ ប្រធាននាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ[illegible]ខែ[illegible] ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ[illegible] ឆ្នាំ២០២០

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ឯកឧត្តមបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

កិត្តិសេដ្ឋាបណ្ឌិត **ចម ប្រសិទ្ធ**

កន្លែងទទួល

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមុខងារសាធារៈ
-ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៤
-រាជកិច្ច
-ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
អគ្គនាយកដ្ឋានកិច្ចការទូទៅ
នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ

តារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រធានថវិកាតាមកម្មវិធីឆ្នាំ២០២០
របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

ឯកតា ៖ រៀល

ជំពូក	គណៈ	អនុគណៈ	បរិយាយ	ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២០	តំណាង ដែលជ្រើសរើស	តំណាង ផ្តេទេយ្យបុរេប្រទាន	តំណាង ទុទាត់ធម្មតា	តំណាន០១ជុំបង្វិល ផ្តេទេយ្យបុរេប្រទាន	អត្រាភាគ រយ%
				1	2	3	4=2-3	5=3/4ជុំ	6=3/2
			សរុបរួម	**21,931,000,000**	**16,543,200,000**	**6,421,200,000**	**10,122,000,000**	**1,605,300,000**	**38.81%**
60			**ការគិញ**	**8,486,800,000**	**6,853,800,000**	**2,756,800,000**	**4,097,000,000**	**689,200,000**	**40.22%**
	6001		**សម្ភារផ្គត់ផ្គង់ថែទាំ**	**851,800,000**	**351,800,000**	**351,800,000**	**-**	**87,950,000**	**100.00%**
		60011	សម្ភារផ្គត់ផ្គង់ សម្ភាត និងអនាម័យ	151,800,000	151,800,000	151,800,000	-	37,950,000	100.00%
		60012	សម្ភារផ្គត់ផ្គង់សម្រាប់ថែទាំអគារ ប្រាសាទ និងសំណង់ផ្សេងៗ	30,000,000	30,000,000	30,000,000	-	7,500,000	100.00%
		60014	សម្ភារផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារឧបករណ៍	170,000,000	170,000,000	170,000,000	-	42,500,000	100.00%
		60015	ប្រេងឥន្ធនៈ និងប្រេងរំអិល	500,000,000	-	-	-	-	0.00%
	6002		**សម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាល**	**1,467,000,000**	**1,467,000,000**	**742,000,000**	**725,000,000**	**185,500,000**	**50.58%**
		60021	សម្ភារការិយាល័យ	776,000,000	776,000,000	356,000,000	420,000,000	89,000,000	45.88%
		60022	សៀវភៅមើល និងឯកសារ	56,000,000	56,000,000	56,000,000	-	14,000,000	100.00%
		60023	ការបោះពុម្ព	600,000,000	600,000,000	295,000,000	305,000,000	73,750,000	49.17%
		60028	សម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាលផ្សេងៗ	35,000,000	35,000,000	35,000,000	-	8,750,000	100.00%
	6004		**សម្លៀកបំពាក់ និងការតុបតែង**	**550,000,000**	**550,000,000**	**60,000,000**	**490,000,000**	**15,000,000**	**10.91%**
		60041	ឯកសណ្ឋាន	530,000,000	530,000,000	40,000,000	490,000,000	10,000,000	7.55%
		60042	សម្លៀកបំពាក់ការពារសុវត្ថិភាព	20,000,000	20,000,000	20,000,000	-	5,000,000	100.00%
	6005		**សម្ភារតូចតាច សង្ហារឹម និងសម្ភារបរិក្ខារ**	**4,165,000,000**	**3,955,000,000**	**1,285,000,000**	**2,670,000,000**	**321,250,000**	**32.49%**
		60051	សម្ភារ និងបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា	1,700,000,000	1,700,000,000	100,000,000	1,600,000,000	25,000,000	5.88%
		60052	សង្ហារឹម	1,380,000,000	1,380,000,000	630,000,000	750,000,000	157,500,000	45.65%
		60053	សម្ភារប្រើប្រាស់	75,000,000	75,000,000	75,000,000	-	18,750,000	100.00%
		60054	សម្ភារៈ និងឧបករណ៍ដឹកជញ្ជូន	210,000,000	-	-	-	-	0.00%
		60055	សម្ភារ និងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា	800,000,000	800,000,000	480,000,000	320,000,000	120,000,000	60.00%
	6006		**ថាមពលនិងទឹក**	**923,000,000**	-	-	-	-	**0.00%**
		60061	អគ្គិសនី	886,000,000	-	-	-	-	0.00%

ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២០ ទទួលអ្នកឆ្លើ ឆ្នាំ ២០២០

		60061	ទឹក	37,000,000	-	-	-	-	0.00%
	6098		**សម្ភារផ្គត់ផ្គង់ផ្សេងៗ**	**530,000,000**	**530,000,000**	**318,000,000**	**212,000,000**	**79,500,000**	**60.00%**
		60981	សម្ភារផ្គត់ផ្គង់ផ្សេងៗ	530,000,000	530,000,000	318,000,000	212,000,000	79,500,000	60.00%
61			**សេវាកម្ម**	**13,444,200,000**	**9,689,400,000**	**3,664,400,000**	**6,025,000,000**	**916,100,000**	**37.82%**
	6101		**កិច្ចសន្យានៃការផ្តល់សេវាជាមួយសហគ្រាស**	**6,000,000**	-	-	-	-	**0.00%**
		61011	សេវាអនាម័យ	6,000,000	-	-	-	-	0.00%
	6102		**ការជួលមធ្យោបាយដឹកជញ្ជូន**	**101,000,000**	-	-	-	-	**0.00%**
		61021	ការជួលមធ្យោបាយដឹកជញ្ជូន	101,000,000	-	-	-	-	0.00%
	6104		**សោហ៊ុយបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស**	**1,461,000,000**	**1,461,000,000**	**200,000,000**	**1,261,000,000**	**50,000,000**	13.69%
		61041	សោហ៊ុយបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស	1,461,000,000	1,461,000,000	200,000,000	1,261,000,000	50,000,000	13.69%
	6105		**ការថែទាំ និងជួសជុល**	**1,520,000,000**	**1,520,000,000**	**920,000,000**	**600,000,000**	**230,000,000**	**60.53%**
		61051	ការថែទាំដីធ្លី សួនច្បារ ព្រៃឈើ តំបន់ឆ្នេរ និងដែននេសាទ	13,000,000	13,000,000	13,000,000	-	3,250,000	100.00%
		61052	ការថែទាំ ជួសជុលអាគារផ្សេងៗ និងប្រាសាទ	880,000,000	880,000,000	280,000,000	600,000,000	70,000,000	31.82%
		61054	ការថែទាំបណ្តាញផ្សេងៗ	200,000,000	200,000,000	200,000,000	-	50,000,000	100.00%
		61056	ការថែទាំ និងជួសជុលមធ្យោបាយដឹកជញ្ជូន	182,000,000	182,000,000	182,000,000	-	45,500,000	100.00%
		61057	ការថែទាំ និងជួសជុលសម្ភារ និងឧបករណ៍បច្ចេកទេស	210,000,000	210,000,000	210,000,000	-	52,500,000	100.00%
		61058	ការថែទាំ និងជួសជុលផ្សេងៗ	35,000,000	35,000,000	35,000,000	-	8,750,000	100.00%
	6107		**សោហ៊ុយសិក្សាពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សោនិងសោហ៊ុយនៃការប្រើប្រាស់**	**65,000,000**	**65,000,000**	**65,000,000**	-	**16,250,000**	**100.00%**
		61071	សោហ៊ុយសិក្សាពិសោធន៍	65,000,000	65,000,000	65,000,000	-	16,250,000	100.00%
	6108		**សោហ៊ុយដឹកជញ្ជូន**	**90,000,000**	**90,000,000**	**70,000,000**	**20,000,000**	**17,500,000**	77.78%
		61081	សម្ភារៈ និងទំនិញ	90,000,000	90,000,000	70,000,000	20,000,000	17,500,000	77.78%
		61088	សោហ៊ុយដឹកជញ្ជូនផ្សេងៗ	0	-	-	-	-	0.00%
	6110		**ទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយ**	**6,054,400,000**	**4,664,400,000**	**1,664,400,000**	**3,000,000,000**	**416,100,000**	**35.68%**
		61101	សោហ៊ុយទទួលភ្ញៀវជាតិ	115,000,000	115,000,000	115,000,000	-	28,750,000	100.00%
		61102	សោហ៊ុយទទួលភ្ញៀវបរទេស	190,000,000	190,000,000	190,000,000	-	47,500,000	100.00%
		61103	ប្រជុំ សិក្ខាសាលា និងសន្និសីទ	4,210,000,000	4,210,000,000	1,210,000,000	3,000,000,000	302,500,000	28.74%
		61104	ចំណាយរៀបចំពិធីបុណ្យ	44,400,000	44,400,000	44,400,000	-	11,100,000	100.00%
		61106	ចំណាយសម្រាប់ការតាំងពិពណ៌នៅក្នុង និងក្រៅប្រទេស	1,390,000,000	-	-	-	-	0.00%
		61107	ការឃោសនា និងផ្សព្វផ្សាយព័ត៌មានសាធារណៈ	70,000,000	70,000,000	70,000,000	-	17,500,000	100.00%
		61108	ទំនាក់ទនងសាធារណៈ និងផ្សព្វផ្សាយផ្សេងៗ	35,000,000	35,000,000	35,000,000	-	8,750,000	100.00%
	6111		**សារពត៌មាន និងឯកសារ**	**40,000,000**	**40,000,000**	**40,000,000**	-	**10,000,000**	**100.00%**
		61111	ចំណាយលើការជាវសារពត៌មាន	10,000,000	10,000,000	10,000,000	-	2,500,000	100.00%
		61112	ចំណាយលើការជាវទស្សនាវដ្តី	10,000,000	10,000,000	10,000,000	-	2,500,000	100.00%
		61118	ចំណាយលើការជាវសារព័ត៌មាន និងឯកសារផ្សេងៗ	20,000,000	20,000,000	20,000,000	-	5,000,000	100.00%

	6112		សោហ៊ុយបេសកកម្មក្នុងប្រទេស	1,849,000,000	1,849,000,000	705,000,000	1,144,000,000	176,250,000	38.13%
		61121	សោហ៊ុយដឹកជញ្ជូន	306,200,000	306,200,000	120,000,000	186,200,000	30,000,000	39.19%
		61122	សោហ៊ុយបេសកកម្ម	220,600,000	220,600,000	85,000,000	135,600,000	21,250,000	38.53%
		61123	សោហ៊ុយស្នាក់នៅ	1,322,200,000	1,322,200,000	500,000,000	822,200,000	125,000,000	37.82%
	6113		សោហ៊ុយបេសកកម្មក្រៅប្រទេស	2,200,000,000	-	-	-	-	0.00%
		61131	សោហ៊ុយដឹកជញ្ជូន	709,000,000	-	-	-	-	0.00%
		61132	សោហ៊ុយបេសកកម្ម	518,000,000	-	-	-	-	0.00%
		61133	សោហ៊ុយស្នាក់នៅ	973,000,000	-	-	-	-	0.00%
	6114		សោហ៊ុយប្រៃសណីយ៍ និងទូរគមនាគមន៍	57,800,000	-	-	-	-	0.00%
		61141	សោហ៊ុយប្រៃសណីយ៍	3,800,000	-	-	-	-	0.00%
		61142	សោហ៊ុយទូរគមនាគមន៍	54,000,000	-	-	-	-	0.00%

បានឃើញ និងពិនិត្យត្រឹមត្រូវ
រាជធានីភ្នំពេញ, ថ្ងៃទី..ខែ.. ឆ្នាំ២០២០
ឧ. ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា
អគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ

ប៊ុញ ប្អាន សុវណ្ណអានិច្ចាសីលា

បានឃើញ និងពិនិត្យត្រឹមត្រូវ
រាជធានីភ្នំពេញ, ថ្ងៃទី..ខែ..ឆ្នាំ២០២០
ឧ. ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា
អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ

កុក-មីម

បានឃើញ និងឯកភាព
ថ្ងៃ... ខែ... ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី..ខែ.. ឆ្នាំ២០២០
ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

បានឃើញ និងពិនិត្យត្រឹមត្រូវ
រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែមករា ឆ្នាំ២០២០
ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា
អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការខុទ្ទកៈ

សឺន-សុថា

បានឃើញ និងឯកភាព
ថ្ងៃសុក្រ ... ខែ... ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី..ខែ.. ឆ្នាំ២០២០
ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងទេសចរណ៍កម្ម និងសិប្បកម្ម

កិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែមករា ឆ្នាំ២០២០
រដ្ឋទេយ្យករបុរេប្រទាន

វ៉ែន លន់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ...

ថ្ងៃ...ខែ...ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..... ខែ..... ឆ្នាំ២០២០

ប្រកាសបង្កើតរោងចក្រ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/ ០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងលិខិតលេខ ៤១៩៩/១៩ គ.វ.ក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំប្រកាសបង្កើតរោងចក្រត្បាញខ្សែបន្ទះ ខ្សែយឺត និងអំបោះដេរ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ក្រុមហ៊ុន ស៊ីន ហាក់ មុយ មេក ខ្លូស អឺស៊ីស មេធៀរៀល ឯ.ក

សម្រេច

ប្រការ១៖ អនុញ្ញាតឱ្យក្រុមហ៊ុន ស៊ីន ហាក់ មុយ មេក ខ្លូស អឺស៊ីស មេធៀរៀល ឯ.ក (XIN HAK MUY MAKE CLOTHES ASSIST MATERIAL CO., LTD.) តំណាងដោយ លោកស្រី LIN, YANHONG បង្កើតរោងចក្រត្បាញខ្សែបន្ទះ ខ្សែយឺត និងអំបោះដេរ ដែលមានទីតាំងស្ថិតនៅ ផ្លូវលេខ២១៧ ភូមិព្រែក កំពឹស សង្កាត់ព្រែកកំពឹស ខណ្ឌដង្កោ រាជធានីភ្នំពេញ។

ឈ្មោះផលិតផល	លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code
១-ខ្សែបន្ទះ និងខ្សែយឺត	១៣៩៩
២-អំបោះដេរ	១៣១១

ប្រការ២៖ ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " រោងចក្រក្បាញខ្សែបន្ទះ ខ្សែយឺត និងអំបោះដេរ ស៊ីន ហាក់ មុយ មេក ខ្លួស អឺស៊ីស មេធៀរៀល ឯ.ក "

ប្រការ៣៖ ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៨នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

ប្រការ៤៖ មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព ០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

ប្រការ៥៖ ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៦៖ ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំងការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៧៖ ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៨៖ ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៩៖ ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១០៖ ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១១៖ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១២៖ លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

ប្រការ១៣៖ ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ប្រការ១៤៖ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការៀងៗខ្លួន។

ប្រការ១៥៖ ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម
ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីការអភិវឌ្ឍន៍ឧស្សាហកម្ម
និងសិប្បកម្ម

ង៉ាន សុភា

ចម្លងជូន៖
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
-វិទ្យាស្ថានស្តង់ដារកម្ពុជា
-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
-សាលារាជធានីភ្នំពេញ
-មន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ
-រដ្ឋបាលខណ្ឌដង្កោ
-រដ្ឋបាលសង្កាត់ព្រែកកំពឹស
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៨ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ :

ថ្ងៃ... ខែ... ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ២០២០

ប្រកាសបង្កើតរោងចក្រ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/ ០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងលិខិតលេខ ៣២៧៤/១៩ គ.វ.ក ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំប្រកាសបង្កើតរោងចក្រផលិតឥដ្ឋគ្រប់ប្រភេទ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៩ របស់ក្រុមហ៊ុន ជីន ថៃ ហុង (ខេមបូឌា) ញូ ប៊ីលឌីង មេធៀរៀ ឯ.ក

សម្រេច

